ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៧៤០
ចុះថ្ងៃទី០២-០៨-២០១៦
សាលដីកា
លេខ ៥៦"ក្រ V ទល"
ចុះថ្ងៃទី១១-០៨-២០២០

## គាទនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-៧-២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាឧទ្ធរណ៍នាថ្ងៃទីដប់ប្រាំពីរ ខែកក្កដា ឆ្នាំពីរពាន់ម្ភៃ ដោយមានសមាសភាពដូចខាងក្រោមះ

### ក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ជាអគ្គព្រះរាជអាជ្ញារង

### ក្រឡាបញ្ជី

លោក [redacted] ក្រឡាបញ្ជីសវនាការ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៧៤០ ចុះថ្ងៃទី០២-០៨-២០១៦ ដែលមានះ

-ជនជាប់ចោទឈ្មោះ [redacted] NASWALL (ព្រាយអិន ដាវីដ ណាស្វែល) ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិអាមេរិក មុខរបរភាគហ៊ុនអាកាសចរ [redacted] AIRLING ទីកន្លែងកំណើតនៅទីក្រុង Winnipig ខេត្ត Manatoba ប្រទេសកាណាដា មានទីលំនៅស្នាក់[redacted] បុរីកីឡា ជាន់ទី០៦ អាគារB ផ្លូវលេខ ២១១ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] "ស" ម្តាយឈ្មោះ[redacted] "ស" ប្រពន្ធឈ្មោះ [redacted]លែងលះ" មានកូន០១នាក់ ទោសពីមុនគ្មាន ។(ប្តឹងឧទ្ធរណ៍)

-ឃាត់ខ្លួនថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៥, ឃុំខ្លួនថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១៥ ។

-លោក[redacted] ឈាំង ជាអ្នកបកប្រែភាសាអង់គ្លេស មកជាភាសាខ្មែរ

-លោក[redacted]សជ្ជសម្ផស្ស មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

<u>ជាប់ចោទពីបទ:</u> ទិញពេស្យាចារកុមារ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១១ ឆ្នាំ២០១៣ ឆ្នាំ២០១៥ និងជាក់ស្តែងនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។



Scanned with CamScanner

២-ដើមបណ្តឹងរដ្ឋប្បវេណី

ក.ឈ្មោះ [redacted] វឿន ភេទស្រី អាយុ៣៧ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅភូមិ [redacted] ស្រុកស្នួល ខេត្តក្រចេះ

ខ.ឈ្មោះ [redacted] រ៉ូហាន់នី ភេទស្រី អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ មានទីលំ [redacted] ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ

គ.ឈ្មោះ [redacted] រំដួល ភេទស្រី អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ មានទីលំ [redacted] សង្កាត់ជ្រោយចង្វារ រាជធានីភ្នំពេញ

ឃ.ឈ្មោះ [redacted] សុខុន ភេទស្រី អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ មានទី [redacted] សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

ង.ឈ្មោះ [redacted] សុខា ភេទស្រី អាយុ២៥ឆ្នាំ សញ្ជាតិខ្មែរ មានទីលំ [redacted] សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ

ច.ឈ្មោះ [redacted] ស្រី ភេទស្រី អាយុ៤៨ឆ្នាំ សញ្ជាតិខ្មែរ មានទីលំ [redacted] ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

ឆ.ឈ្មោះ [redacted] យាន ភេទស្រី អាយុ៤៨ឆ្នាំ សញ្ជាតិខ្មែរ មានទីលំ [redacted] ស្រុកចំការលើ ខេត្តកំពង់ចាម ។

**លោក ឯក សុធា មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី**

**៣-ជនរងគ្រោះ**

ក.ឈ្មោះ [redacted] ស្រីម៉ៅ ភេទស្រី អាយុ១៥ឆ្នាំ កើតថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០០ សញ្ជាតិខ្មែរ មានទីលំនៅស្នាក់នៅក្នុងមជ្ឈមណ្ឌលកម្ពុជាដើម្បីសិទ្ធិកុមារ (ម.ក.ក. [redacted] កក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ខ.ឈ្មោះ [redacted] មុនីរត្ន ភេទស្រី អាយុ ៥ឆ្នាំ កើតថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ សញ្ជាតិខ្មែរ មានទីលំនៅភូ [redacted] ខណ្ឌ៧មករា រាជធានីភ្នំពេញ។

គ.ឈ្មោះ [redacted] ស្រីឃីម ភេទស្រី អាយុ ៧ឆ្នាំ កើតថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៨ សញ្ជាតិខ្មែរ មានទីលំនៅ [redacted] ខណ្ឌ៧មករា រាជធានីភ្នំពេញ។

ឃ.ឈ្មោះ [redacted] សុភីនីផុតមុន្នី ភេទស្រី អាយុ ៦ឆ្នាំ កើតថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៩ សញ្ជាតិខ្មែរ មានទីលំនៅ [redacted] ខណ្ឌ៧មករា រាជធានីភ្នំពេញ។

ង.ឈ្មោះ [redacted] ស្រីណែត ភេទស្រី អាយុ ១៣ឆ្នាំ កើតឆ្នាំ២០០២ សញ្ជាតិខ្មែរ មានទីលំនៅផ្ទះជួល [redacted] រាជធានីភ្នំពេញ។

ច.ឈ្មោះ [redacted] សុភ័ក្រ ភេទស្រី អាយុ១៦ឆ្នាំ សញ្ជាតិខ្មែរ (ស្នាក់នៅសហគមន៍ទឹកដីសន្យា) ផ្ទះ [redacted] ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

ឆ. ឈ្មោះ [redacted] ស្រីសស់ ភេទស្រី អាយុ១៥ឆ្នាំ សញ្ជាតិខ្មែរ (ស្នាក់នៅសហគមន៍ទឹកដីសន្យា) ផ្ទះ [redacted] ក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

ជ. ឈ្មោះ [redacted] ស៊ីល័ក្ខ ភេទស្រី អាយុ១៣ឆ្នាំ សញ្ជាតិខ្មែរ (ស្នាក់នៅ [redacted]



Scanned with CamScanner

លេខ០៥២៨ ផ្លូវលំបឹងកក់តូច ភូមិស្វាយតារុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

ឈ. ឈ្មោះ [redacted] ស្រីពៅ ភេទស្រី អាយុ១៣ឆ្នាំ កើតថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០២ សញ្ញាតិខ្មែរ (ស្ន [redacted] ភូមិត្បោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

## ៦រឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ វេលាប្រហែល១៩ និង០០នាទី នៅចំណុចកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] NASWALL ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិអាមេរិក បានជិះម៉ូតូឌុបកុមាររងគ្រោះចំនួន បីនាក់ មានឈ្មោះ [redacted] ស្រីល័ក្ខ ភេទស្រី អាយុ១៣ឆ្នាំ, ឈ្មោះ [redacted] សុភ័ក្រ ភេទស្រី អាយុ១៦ឆ្នាំ និងឈ្មោះ [redacted] ស្រីរ័ត្ន ភេទស្រី អាយុ១៥ឆ្នាំ ដើរលេងហូបនំចំណី និងទិញសំភារៈផ្សេងៗឱ្យជនរងគ្រោះ ។ ពេលមកដល់កោះពេជ្រកន្លែងស្ងាត់ ខាងក្រោយឃ្លាំងដាក់ឥវ៉ាន់ ជនសង្ស័យឈ្មោះ [redacted] Naswall ក៏បានឈប់ម៉ូតូរួចក៏ស្រ [redacted] វិញ ដោយកុមាររងគ្រោះ ឈ្មោះ [redacted] ស្រីល័ក្ខ ដាក់អង្គុយលើម៉ូតូ រួចជនជាប់ចោទបានយ [redacted] រងគ្រោះវិញ ។ ជនជាប់ចោទបានសន្យាឱ្យប្រាក់ទៅកុមារនារីរងគ្រោះទាំងអស់នោះក្នុងម្នាក់ៗ ចំនួន ១៥ដុល្លារអាមេរិក ទៅ២០ដុល្លារអាមេរិក ក្រោយពីជនសង្ស័យឈ្មោះ [redacted] Naswall បានធ្វើសកម្មភាពបានប្រហែល ០៧នាទី ក៏ត្រូវសមត្ថកិច្ចចូលទៅធ្វើការឃាត់ខ្លួនតែម្តង ។ កន្លងមកនៅឆ្នាំ ២០១១, ឆ្នាំ២០១៣, ឆ្នាំ២០១៥ ជនជាប់ចោទឈ្មោ [redacted] Naswall ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិអាមេរិក ក៏បានធ្វើសកម្មភាពដូចនេះទៅលើកុមាររងគ្រោះជាច្រើននាក់ផ្សេងទៀតមកហើយ ។

-**បានឃើញ** ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] Naswall បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលសវនាការប្រហាក់ប្រហែលគ្នាថា ៖ កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ វេលាម៉ោង ១៩និង០០នាទី ទៅ ២០និង០០នាទី មានក្មេងស្រីម្នាក់ ដែលខ្លួនធ្លាប់ស្គាល់នៅមាត់ទន្លេ តែមិនស្គាល់ឈ្មោះ បានទូរស័ព្ទមកខ្លួនសុំឱ្យខ្លួននាំនាងទៅលេងខ្រឹមលេន ប៉ុន្តែពេលនោះខ្លួនបានប្រាប់នាងថាជាប់រវល់ ។ បន្ទាប់ពីនិយាយទូរស័ព្ទចប់ ខ្លួនបានជិះម៉ូតូធំចេញពីផ្ទះទៅរកហូបអី ពេលជិះម៉ូតូមកដល់ម្តុំមាត់ទន្លេ ស្រាប់តែក្មេងស្រី ដែលបានទូរស័ព្ទមកខ្លួនបានឃើញខ្លួន ហើយក៏ស្រែកហៅឱ្យឈប់ ។ ពេលនោះខ្លួនឃើញមានគ្នាចំនួន ០៣នាក់ រួចក៏ឱ្យខ្លួនជូនទៅលេងខ្រឹមលេន ទាំងបីនាក់ ដោយជិះម៉ូតូជាមួយគ្នាទាំងអស់ ។ បន្ទាប់ពីដើរលេងខ្រឹមលេន ដោយជិះកន្ត្រកវិល និងបានញ៉ាំអីរួចមក ពួកនាងក៏បានឱ្យខ្លួនជូនទៅគប់ប៉េងប៉ោងនៅកោះពេជ្រ ក្រោយពីគប់ប៉េងប៉ោងនៅកោះពេជ្រ ក្រោយពីគប់ប៉េងប៉ោងនៅកោះពេជ្រចប់ ខ្លួនក៏បានឌុបពួកនាងទៅកន្លែងមួយ ដែលមិនសូវមានមនុស្ស ប៉ុន្តែមិនស្ងាត់ពេកទេ ក្នុងបំណងទៅបត់ជើងតូច ។ ពេលខ្លួនឈប់ម៉ូតូក្មេងស្រី ដែលជិះទៅជាមួយ គឺបានដើរចេញពីខ្លួន ប៉ុន្តែមិនឆ្ងាយទេ រួចក៏ដើរទៅបត់ជើង ក្រោយពីបត់ជើងរួច ខ្លួនក៏មកកន្លែងម៉ូតូវិញ ស្រាប់តែមានមនុស្សប្រហែល ៥ទៅ៦នាក់ បានឈ្លូលពិលមករកខ្លួន ហើយស្រែកថា ប៉ូលីសៗ ហើយប្រាប់ខ្លួនថា និងនាំខ្លួនទៅកន្លែងប៉ូលីស ដោយសារខ្លួនបានរួមភេទជាមួយអនីតិជន ហើយខ្លួនក៏យល់ព្រមទៅជាមួយប៉ូលីស ។ ពេលខ្លួនឈប់ម៉ូតូនៅកន្លែងស្ងាត់ គឺមិនបានឱ្យក្មេងៗទាំងនោះ ព [redacted]



Scanned with CamScanner

[redacted] ក្មេងស្រីៗទាំងនោះដែរ ហើយក៏មិនបានសន្យាទិញសំភារៈ និងលុយកាក់ដល់ក្មេងៗទេ ហើយកន្លងមក ក៏មិនដែលបានធ្វើអំពើដូចការចោទប្រកាន់ដែរ ។ ក្មេងស្រីៗទាំងបីនាក់ដែលខ្លួនជូនដើរលេង នៅយប់កើតហេតុ គឺខ្លួនធ្លាប់ស្គាល់ពួកនាង ដោយសារធ្លាប់ឃើញពួកនាងដើរលេងនៅម្តុំមាត់ទន្លេ ជាច្រើនលើកច្រើនសារ គឺមិនស្គាល់ឈ្មោះទេ ស្គាល់តែមុខ ហើយក៏មិនដែលមានទំនាក់ទំនងផ្លូវភេទជាមួយពួកនាងទេ ។ ខ្លួនធ្លាប់ស្គាល់ក្មេងបានប្រហែល មួយឆ្នាំ ទៅពីរឆ្នាំ និងធ្លាប់ដើរលេងបានប្រហែល ៣ដង និងធ្លាប់ឱ្យលុយ នាងផងដែរ ប៉ុន្តែមិនដែលបានឱ្យលើសពី ១ដុល្លានោះទេ ហើយក៏មិនដែលសន្យាឱ្យប្រាក់នាងពី ២០ ទៅ ៣០ដុល្លានោះទេ ។

-បានឃើញ ចម្លើយរបស់ជនរងគ្រោះឈ្មោះ[redacted]ស្រីណែត បានឆ្លើយនៅដំណាក់កាលស៊ើបសួរ និងដំណាក់កាលសវនាការ ប្រហាក់ប្រហែលគ្នាថា ៖ ខ្លួនស្គាល់ឈ្មោ[redacted] Naswall តាំងពីឆ្នាំ ២០១៣ ហើយបានដើរលេងជាមួយគាត់បានចំនួន ០២ដង ។ លើកទី១ នៅក្នុងខែកក្កដា ឆ្នាំ២០១៣ វេលាម៉ោង ១៩និង០០នាទី ខ្លួនបានដើរលេងជាមួយឈ្មោះ [redacted] នាង បានជិះម៉ូតូធំ ជាមួយឈ្មោះ [redacted] Naswall នៅសួនច្បារកោះពេជ្រ ទៅដល់កន្លែងស្ងាត់ គាត់បានឱ្យខ្លួន និង[redacted] នាង លេង [redacted] គាត់ រួចគាត់បានឱ្យប្រាក់ចំនួន ៥ដុល្លាអាមេរិកចែកគ្នា ។ លើកទី២ បន្ទាប់ពីលើកទី១ ប្រហែល៥ថ្ងៃ ពេលនោះខ្លួនទៅជាមួយឈ្មោះ [redacted] ពៅ នៅពេលយប់ ឈ្មោះ [redacted]Naswall បានឱបពួកខ្លួនទាំងពីរនាក់ ដើរលេងសួរច្បារសម្តេចហ៊ុន សែន ពេលដល់កន្លែងស្ងាត់ គាត់បានឱ្យរូបខ្លួន និង [redacted] ម៉ៅ [redacted] របស់គាត់ រួចខ្លួន និង [redacted] ម៉ៅ [redacted] រួចគាត់បានឱ្យប្រាក់ ៥ដុល្លារ ចែកគ្នា ។ ក្រោយមកទៀតក្នុងឆ្នាំ ២០១៤ និងឆ្នាំ ២០១៥ ខ្លួនមិនដែលបានជួបឈ្មោះ [redacted] Naswall ទៀតទេ។

-បានឃើញ ចម្លើយរបស់ជនរងគ្រោះឈ្មោះ[redacted] ស្រីរ័ត្ន បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលសវនាការ ប្រហាក់ប្រហែលគ្នាថា ៖ ខ្លួនបានដើរលេងជាមួយឈ្មោះ [redacted] Naswall បានចំនួន ២ដង ។ នៅថ្ងៃមិនចាំ ឆ្នាំ២០១៣ វេលាម៉ោង ២៣ និង ០០ នាទី ខ្លួនបានជួបជនបរទេសម្នាក់ឈ្មោះ [redacted]Naswall នៅមាត់ទន្លេ ជាមួយមិត្តភក្តិឈ្មោះ [redacted] ម៉ៅ និង ស្រីនាង បានជូនពួកខ្លួនជិះម៉ូតូធំដើរលេង ។ នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០១៥ វេលាម៉ោង ២០ និង ៣០នាទី ខ្លួន និងបងស្រីឈ្មោះ [redacted] ពៅ បានអង្គុយ លេងនៅមាត់ទន្លេ ហើយបានជួបឈ្មោះ ភ័ក្រ ហៅ អូន និងឈ្មោះ [redacted] ល័ក្ខ ហៅ ពេជ្រ ក៏បាននាំខ្លួនទៅដើរលេងជាមួយឈ្មោះ [redacted]Naswall ចំណែកប្អូនរបស់ខ្លួនឈ្មោះ [redacted] ពេជ្រ មិនបានទៅទេ ។ ឈ្មោះ [redacted]Naswall បានឱបពួកនាងទៅលេងកោះពេជ្រកន្លែងការដ្ឋានសាងសង់ស្ងាត់មួយ [redacted] ភេទរបស់គាត់ ដោយគាត់បានសន្យាឱ្យប្រាក់មកខ្លួន និងឈ្មោះ [redacted] អូន ម្នាក់ចំនួន ១៥ដុល្លារ ឯឈ្មោះ [redacted] ពេជ្រ ចំនួន ២០ដុល្លារ តែខ្លួន និងឈ្មោះ[redacted] ន មិនព្រមយក រួចគាត់ឱ្យឈ្មោះ [redacted]ពេជ្រ ឡើងអង្គុយលើកែបម៉ូតូលេ[redacted]ពេជ្រ វិញ ប៉ុន្តែ[redacted]ផង ស្រាប់តែសមត្ថកិច្ចមកដល់ ។



Scanned with CamScanner

-បានឃើញ ចម្លើយរបស់ជនរងគ្រោះឈ្មោ[redacted] សុភ័ក្រ បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលសវនាការប្រហាក់ប្រហែលគ្នាថា ៖ ខ្លួនស្គាល់ឈ្មោះ [redacted] Naswall តាំងពីឆ្នាំ ២០១៤ នៅពេលដែលខ្លួនបានដើររើសអេតចាយនៅមាត់ទន្លេ និងគាត់ធ្លាប់ឱ្យប្រាក់មកខ្លួនចំនួន ៣ដង ពី១ដង ទៅ ៥០០០រៀល និងធ្លាប់ដើរលេងជាមួយគាត់បានចំនួន ៣ដង ដែរ និង[redacted]ក់ម្តង គាត់បានឱ្យប្រាក់ ១០ដុល្លា ។ នៅថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៥ វេលាម៉ោង ២០ និង០០នាទី ខ្លួនបានឱ្យប្រាក់ ១០ដុល្លា ។ នៅថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១៥ វេលាម៉ោង ២០ និង០០នាទី ខ្លួនបានជួបឈ្មោះ [redacted] Naswall រួចក៏បបួលពួកខ្លួន ជិះម៉ូតូដើរលេង មានខ្លួន ,ឈ្មោះ សុភ័ក្រ និងឈ្មោ[redacted]រ័ត្ន ចំណែកឈ្មោះ ស្រីពៅ មិនបានទៅទេ ។ ក្នុងពេលពួកខ្លួនជិះកន្ត្រកវិល ជាមួយឈ្មោះ [redacted] Naswall គឺគាត់ឱ្យពួកខ្លួនទាំងបី លេ[redacted]ឱ្យពួកខ្លួនលេង ហើយឈ្មោះ [redacted] Naswall ក៏បាន[redacted]ទាំងបីនាក់វិញផងដែរ រហូតដល់កន្ត្រកលែងវិលទើបឈប់លេង ។ ឈ្មោះ Brain David Naswall បានសន្យាឱ្យប្រាក់ក្នុងម្នាក់ៗ ១០ដុល្លា ។ បន្ទាប់មកក៏បានឌុបពួកខ្លួនទៅកោះពេជ្រ ពេលទៅដល់កន្លែងមួយដែលគេព័ទ្ធសង្ក័ស៊ីជិតសន្តិសុខយាម យប់ស្ងាត់ ឈ្មោះ [redacted]Naswall ក៏បានឱ្យពួកខ្លួនទាំងបីនាក់[redacted]ភេទរបស់គាត់ទៀត ដោយបានសន្យាឱ្យប្រាក់មកខ្លួន និងឈ្មោះ ស្រី រ័ត្ន ក្នុងម្នាក់ ៥ដុល្លាថែមទៀត ចំណែកឈ្មោះ [redacted] ល័ក្ខ គឺគាត់ថែមឱ្យ១០ដុល្លា ។ ពេលនោះខ្លួន និងឈ្មោះ[redacted] ល័ក្ខ [redacted] ហើយឈ្មោះ [redacted] Naswall ក៏ឱ្យពួកខ្លួនទាំងពីរឈរឆ្ងាយ ដើម្បីចាំមើលផ្លូវឱ្យគាត់ ។ ពេលនោះខ្លួនឃើញឈ្មោះ [redacted] Naswall ស្រាតខោ[redacted] ល័ក្ខ ត្រឹមជង្គង់ ដាក់នាងឱ្យអង្គុយលើម៉ូតូ ហើយឈ្មោះ [redacted] Naswall ក៏បានអោនមុខទៅ[redacted]ឈ្មោះ ស្រី ល័ក្ខ ពេលនោះខ្លួនក៏ងាកមុខចេញ ស្រាប់តែមានសមត្ថកិច្ចមកចុះចាប់ខ្លួនតែម្តង ។ កន្លងមកពេលដែលខ្លួនដើរលេងជាមួយឈ្មោះ [redacted] ណែត និងឈ្មោះ [redacted] ម៉ៅ គឺធ្លាប់បានឃើញឈ្មោះ [redacted] Naswall ឱ្យឈ្មោ[redacted] ម៉ៅ និងឈ្មោះ[redacted] ណែ[redacted]នៅកោះពេជ្រផងដែរ ។ ប៉ុន្តែមិនបានដឹងថាឈ្មោះ [redacted] Naswall ឱ្យលុយទៅឈ្មោះ [redacted] ម៉ៅ និង[redacted]ណែត ប៉ុន្មានទេ ។

-បានឃើញ ចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីល័ក្ខ បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលសវនាការប្រហាក់ប្រហែលគ្នាថា ៖ ខ្លួនស្គាល់ឈ្មោះ [redacted]Naswall នៅមាត់ទន្លេតាមរយៈឈ្មោះ ភ័ក្រ ភេទស្រី ក្នុងឆ្នាំ ២០១៥ ។ នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០១៥ វេលាម៉ោង ១៩ និង០០ នាទី ខ្លួនដើរលេងនៅមាត់ទន្លេជិតផ្សារកណ្តាល មានគ្នា ៤នាក់ មានឈ្មោះ ភ័ក្រ ភេទស្រី អាយុ១៦ឆ្នាំ, ឈ្មោះ ស្រីរ័ត្ន អាយុ ១៥ឆ្នាំ, ឈ្មោះ [redacted]ពៅ អាយុ១៨ឆ្នាំ និងរូបខ្លួន ស្រាប់តែឈ្មោះ [redacted]Naswall បានជិះម៉ូតូមកឈប់ក្បែរពួកខ្លួន រួចបបួលពួកខ្លួនទៅដើរលេងនៅឌ្រីមលែន រួចពួកខ្លួនបីនាក់ក៏ព្រមទៅ ដោយឡែក ឈ្មោះ [redacted] ពៅ មិនបានទៅជាមួយទេ ។ ទៅដល់ឌ្រីមលែន ឈ្មោះ [redacted]Naswall បានទិញការ៉េមឱ្យពួកខ្លួន គប់ប៉េងប៉ោង និងជិះកន្ត្រកវិល ។ ក្រោយពីលេងនៅឌ្រីមលេន រួចឈ្មោះ [redacted]Naswall បានឌុបពួកខ្លួនទៅកោះពេជ្រ ។ ដល់កន្លែងស្ងាត់ក្រោយឃ្លាំងធំមួយ គាត់បានឱ្យ[redacted]ហើយគាត់សន្យាឱ្យប្រាក់ខ្លួនចំនួន ២០ដុល្លា រួចខ្លួនក៏ព្រមលេង ចំណែកឈ្មោះ ភ័ក្រ និងឈ្មោះ ស្រីរ័ត្ន ក៏ឈ្មោះ [redacted]Naswa[redacted]



Scanned with CamScanner

ភេទរបស់គាត់ដែរ ដោយសន្យាឱ្យប្រាក់ចំនួន ១៥ដុល្លារដែរ ។ [redacted] ។

បន្ទាប់មកឈ្មោះ [redacted] Naswall ក៏បាន [redacted]នប្រហែល ៣នាទី ក៏ស្រាប់តែសមត្ថកិច្ចមកឃាត់ខ្លួនតែម្តង ។

-បានឃើញ ចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីម៉ៅ បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលសវនាការប្រហាក់ប្រហែលគ្នាថា ៖ ខ្លួនស្គាល់ជនបរទេសឈ្មោះ [redacted] Naswall តាំងពីខ្លួនមានអាយុ ១៤ឆ្នាំ ដោយគាត់ធ្លាប់បានឱ្យប្រាក់មកខ្លួនចាយម្តងៗ ចំនួន ១ ដុល្លារ ។ ខ្លួនធ្លាប់បានដើរលេងជាមួយគាត់ បានចំនួន ៣ទៅ៤ដង ។ លើកទី១ មិនចាំថ្ងៃខែឆ្នាំ ២០១១ វេលាម៉ោង ២៤ និង ០០នាទី ខ្លួនបានទៅជាមួយស្រីណែត ជិះម៉ូតូធំរបស់គាត់ដើរលេង នៅខ្រឹមលេន និងកោះពេជ្រ កន្លែងស្ងាត់ គាត់បានឱ្យខ្លួន និងឈ្មោះ ស្រីណែត [redacted] ដោយគាត់បានសន្យាឱ្យប្រាក់ ៥ដុល្លារ ក្នុងម្នាក់ៗ ប៉ុន្តែពួកខ្លួនមិនព្រម ក៏ដឹកពួកខ្លួនទៅដាក់នៅមាត់ទន្លេវិញ ។ លើកទី២ រូបខ្លួនជាមួយឈ្មោះ ស្រីណែត និងឈ្មោះ ស្រីនាង បានជួបឈ្មោះ [redacted] Naswall នៅសូរីយាម៉ល គាត់បានឱ្យរូបខ្លួន និងឈ្មោះ ស្រីណែត [redacted]ចគាត់បានឱ្យប្រាក់ខ្លួនម្នាក់ៗ ១០ដុល្លារ ។ លើកទី៣ នៅថ្ងៃមិនចាំ វេលាម៉ោង ០១យប់ ឈ្មោះ [redacted] Naswall បានយកឡានមកដឹកខ្លួន, ឈ្មោះ ស្រីណែត និង ស្រីនាង ទៅលេងនៅម្តុំផ្សារកណ្តាល ពេលទៅដល់គាត់បានឈប់ឡានបិទភ្លើងក៏បានឱ្យពួកខ្លួនទាំងបីនាក់ [redacted] រួចគាត់បានឱ្យប្រាក់ពួកខ្លួនក្នុងម្នាក់ៗ ១០ដុល្លារ ។ លើកទី៤ ថ្ងៃខែមិនចាំ វេលាម៉ោង ១យប់ ឈ្មោះ [redacted] Naswall បានយកឡានមកដឹកពួកខ្លួនមានគ្នា ៤នាក់ ឈ្មោះ ស្រីណែត, ឈ្មោះ ស្រីនាង, ឈ្មោះ ស្រីរ័ត្ន ទៅដើរលេង ពេលជិះដល់ផ្លូវលេខ ១៣៦ ឈ្មោះ [redacted] Naswall ក៏បានឈប់ឡាន រួចក៏បានឱ្យខ្លួនទាំងបួននា[redacted] គាត់ រហូតបានសម្រេចគាត់បានឱ្យប្រាក់ម្នាក់ៗ ១០ដុល្លារ ។ នៅថ្ងៃសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ [redacted] Naswall គឺខ្លួនមិនបានដឹងទេ ព្រោះខ្លួនមិនបានទៅជាមួយគាត់ ។

-បានឃើញ ចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] មុនីរ័ត្ន បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលសវនាការប្រហាក់ប្រហែលគ្នាថា ៖ ជនបរទេសជិះម៉ូតូធំ គាត់រស់នៅជិតផ្ទះខ្លួន ហើយគាត់ធ្លាប់ហៅខ្លួនឡើងទៅលេងផ្ទះគាត់ ចំនួន ៤ដង និងធ្លាប់បានឱ្យប្រាក់មកខ្លួន ចំនួន ៤ ដង ក្នុងម្តងៗ ចំនួន ២០០០រៀល ។ ពេលទៅដល់ផ្ទះគាត់ គឺមានរូបខ្លួន និងឈ្មោះ [redacted] សុភីនីផិតុមុន្នី ភេទស្រី និងឈ្មោះ គួន ភេទប្រុស ហើយគាត់បានចាប់ដៃខ្លួន ឱ្យលេងប្រដាប់ភេទរបស់គាត់ ។

-បានឃើញ ចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីយឹម បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលសវនាការប្រហាក់ប្រហែលគ្នាថា ៖ ខ្លួនស្គាល់ឈ្មោះ [redacted] Naswall ព្រោះគាត់រស់នៅជាន់ទី៦ ជិតផ្ទះខ្លួន ។ នៅថ្ងៃមិនចាំ ឆ្នាំ ២០១៥ តាបារាំងគាត់តែងតែបក់ដៃហៅខ្លួន ឡើងទៅលើផ្ទះរបស់គាត់ នៅជាន់ទី៦ និងធ្លាប់ឱ្យប្រាក់មកខ្លួនជាច្រើនដង ពីចំនួន ៥០០រៀល ទៅ ១០០០រៀល ។ ពេលខ្លួនឡើងទៅលើផ្ទះគាត់ បាន[redacted]ស់គាត់ ពីលើខោលីអូ ។ ចំណែកឈ្មោះ [redacted] សុភីនីផុតិមុន្នី ហៅ តី ក៏បានលេងផងដែរ រួចគាត់ឱ្យប្រាក់មកខ្លួន និងឈ្មោះ [redacted] សុភីនីផុតិមុន្នី ម្នាក់ៗចំនួន ១០០០រៀល ។



Scanned with CamScanner

-ធានឃើញ ចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] សុភីនីផុតិបុន្នី បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលសវនាការប្រហាក់ប្រហែលគ្នាថា ៖ ខ្លួនបានស្គាល់តាបារាំង ព្រោះគាត់ស្នាក់នៅក្នុងបុរីកីឡាដែរ គាត់បានឱ្យខ្លួន និងឈ្មោ[redacted]ស្រីយឹម ហៅ គា ទៅផ្ទះគាត់ ដោយគាត់ឱ្យប្រាក់ម្នាក់ៗ ១០០០រៀល ។ ក្រោយមកតាបារាំង ហៅខ្លួន និងឈ្មោះ គា ចូលទៅផ្ទះរបស់គាត់ គាត់ស្លៀកខោលីអូរអត់មានពាក់អាវទេ ហើ[redacted]ពីខាងក្រៅខោ ពេលនោះពួកខ្លួនមានការភិតភ័យ ក៏នាំគ្នាចុះមកក្រោមវិញដោយបានប្រាប់រឿងហេតុនេះទៅដល់យាយ ។

-ធានឃើញ ចម្លើយរបស់ជនរងគ្រោះឈ្មោះ[redacted] ស្រីពៅ បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលសវនាការប្រហាក់ប្រហែលគ្នាថា ៖ ខ្លួនធ្លាប់ដើរលេងជាមួយឈ្មោះ [redacted]Naswall បានប្រហែល ៥ទៅ ៦ដង មកហើយ គឺទៅដើរលេងនៅឌ្រីមលេន និងនៅកោះពេជ្រ នៅក្នុងម៉ោង២១ និង ០០នាទី ដោយមានឈ្មោះស្រីរ័ត្ន ,ឈ្មោះស្រីភ័ក្រ និងឈ្មោះភ្លាម បានជិះម៉ូតូធំ ឈ្មោះ [redacted] Naswall ទៅដើរលេងនៅកោះពេជ្រ ពេលទៅដល់កោះពេជ្រ ដល់កន្លែងស្ងាត់ ឈ្មោះ [redacted]aswall បានឈប់ម៉ូតូ ហើយក៏បានឱ[redacted]រហូតបានសម្រេច [redacted]ហើយគាត់បានឱ្យប្រាក់ក្នុងម្នាក់ៗ ១០ដុល្លា ។ នៅថ្ងៃដែលសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ [redacted]Naswall គឺខ្លួនមិនបានទៅជាមួយគាត់ទេ ហើយអ្នកដែលទៅជាមួយគាត់មានឈ្មោះ ស្រីរ័ត្ន ជាបងស្រីខ្លួន ឈ្មោះ ស្រីភ័ក្រ និងឈ្មោះ ស្រីពេជ្រ ។ ចំណែកខ្លួននៅអង្គុយចាំបងនៅមាត់ទន្លេ រហូតដល់ម៉ោង ២ និង០០នាទី យប់ ស្រាប់តែមីងរបស់ ស្រីណែត មកប្រាប់ខ្លួនថា បងស្រីខ្លួនឈ្មោះ ស្រីរ័ត្ន ត្រូវសមត្ថកិច្ចឃាត់ខ្លួនជាមួយឈ្មោះ[redacted]aswall ។

-ធានឃើញ ចម្លើយរបស់ដើមបណ្តឹងឈ្មោះ[redacted] សុខន បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលសវនាការប្រហាក់ប្រហែលគ្នាថា ៖ ខ្លួនជាម្តាយបង្កើតរបស់ឈ្មោះ[redacted] ស្រីពៅ ភេទស្រី អាយុ១៣ឆ្នាំ និងឈ្មោះ[redacted] ស្រីរ័ត្ន ភេទស្រី អាយុ១២ ឆ្នាំ ។ នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ វេលាម៉ោង ២០ និង ០០នាទី ពេលខ្លួននៅផ្ទះ ស្រាប់តែកូនរបសខ្លួនឈ្មោះ ស្រី រ័ត្ន និង ស្រី ពៅ បានសុំប្រាក់ពីខ្លួនចំនួន ២០ដុល្លា ថាទៅទិញស្បែកជើង និងខោអាវនៅផ្សាររាត្រី ។ បន្ទាប់ពីពួកគេចេញពីផ្ទះក៏បាត់រហូតដល់វេលាម៉ោង ១យប់ ទើបឃើញកូនរបស់ខ្លួន ឈ្មោះ ស្រី ពៅ បានមកដល់ហើយប្រាប់ខ្លួនថា ស្រី រ័ត្ន បានទៅជាមួយឈ្មោះ [redacted]Naswall ហើយត្រូវគេចាប់បាត់ហើយ ។ ពេលនោះខ្លួនដើររកកូនមិនឃើញ ដល់ស្អែកឡើង ទើបឃ្មមានសមត្ថកិច្ចបានទូរស័ព្ទមកប្រាប់ ។ ចំពោះរឿងហេតុដែលជនបរទេស បាននាំកូនខ្លួន [redacted]ទ ខ្លួនសុំប្តឹងទាមទារសំណងជម្ងឺចិត្តចំនួន ៦០០០(ប្រាំមួយពាន់)ដុល្លារអាមេរិក ។

-ធានឃើញ ចម្លើយរបស់ដើមបណ្តឹងឈ្មោ[redacted] រ៉ដ្ឋល បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលសវនាការប្រហាក់ប្រហែលគ្នាថា ៖ ខ្លួនជាម្តាយបង្កើតរបស់ឈ្មោះ [redacted] ស្រីណែត ភេទស្រី អាយុ១៣ឆ្នាំ រឿងហេតុដែលជនបរទេសឈ្មោះ រឿងហេតុដែលជនបរទេសឈ្មោះ [redacted] Naswall បាននាំកូនទេ[redacted]គឺខ្លួនពុំបានដឹងទេខ្លួនទើបតែបានដឹងថានៅពេលដែលចាប់ជនបរទេសនោះទេ។ កន្លងមកកូនខ្លួនក៏បានប្រាប់ថា វាពិតជាបានដើរលេងជាមួយជនបរទេសនោះពិតមែន ប៉ុន្តែ[redacted]។ក្នុងរឿងនេះខ្លួន



Scanned with CamScanner

មិនប្តឹងទាមទារសំណងអ្វីទេ។

-**បានឃើញ** ចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] ស្រី បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលសវនាការប្រហាក់ប្រហែលគ្នាថា៖ ខ្លួនជាម្តាយបង្កើតរបស់ឈ្មោះ [redacted] ស្រីលក្ខិ៍ ហៅ ស្រីខូច ភេទ ស្រី អាយុ ១១ ឆ្នាំ នៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥ ពេលខ្លួនមកពីធ្វើការវិញ វេលាម៉ោង ៩និង ០០ នាទីព្រឹក ស្រាប់តែបាត់កូនស្រីឈ្មោះ [redacted] ស្រីលក្ខិ៍ ពីផ្ទះដោយមិនបានដឹងថា វាទៅណានោះទេ រហូតដល់ស្អែកក៏មិនឃើញវាត្រលប់មកផ្ទះវិញ រួចខ្លួនក៏បានដើរទៅរកកូន។ ពេលនោះស្រាប់តែមានអ្នកលក់រថយន្តនៅជិតវត្តភ្នំ ប្រាប់ថាមានជនបរទេសម្នាក់ បានលួងលោមក្មេងស្រីចំនួន ០៣ នាក់អោយលេងប្រជាប់ភេទ នៅម៉ុតៀនរបងកោះពេជ្រ ហើយត្រូវបានប៉ូលីសទន្លេបាសាក់ចាប់ខ្លួន។ ចំពោះរឿងហេតុដែលជនបរទេសបាននាំកូនអោយទៅលេងប្រដាប់ភេទ គឺខ្លួនមិនបានឃើញផ្ទាល់ភ្នែកទេ ។ ក្នុងរឿងនេះ ខ្លួនប្តឹងទាមទារជំងឺចិត្តចំនួន ៣០០០ ដុល្លារអាមេរិក ។

-**បានឃើញ** ចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] សុខា បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលសវនាការប្រហាក់ប្រហែលគ្នាថា ៖ ខ្លួនជាម្តាយបង្កើតរបស់ឈ្មោះ [redacted] ស្រីឃីម ភេទស្រី អាយុ៧ឆ្នាំ និងឈ្មោះ [redacted] មុនីរ័ត្ន ភេទស្រី អាយុ ៥ឆ្នាំ ។ នៅក្នុងខែមេសា ឆ្នាំ២០១៥ កូនស្រីរបស់ខ្លួនឈ្មោះ [redacted] ស្រីឃីម បានមកប្រាប់ថា ឈ្មោះ [redacted] Naswall បានហៅវាឱ្យទៅលេងផ្ទះរបស់គាត់ រួចគា [redacted] ។ ក្រោយពីប្រាប់ខ្លួនរួច ខ្លួនក៏ប្រាប់កូនថា ថ្ងៃក្រោយឈប់ទៅលេងជាមួយទៀត ។ រំលងបានបីថ្ងៃជនបរទេសនោះ បានមករកកូនខ្លួនដល់ផ្ទះ ប៉ុន្តែខ្លួនមិនបានឱ្យទៅជាមួយនោះទេ ។ ចំពោះរឿងហេតុដែលជនបរទេសនោះ ហៅកូន [redacted] ខ្លួនមិនបានឃើញទេ ដឹងតាមកូនប្រាប់តែប៉ុណ្ណោះ ក្នុងរឿងនេះ ខ្លួនប្តឹងទាមទារជម្ងឺចិត្តចំនួន ៣០០០ (បីពាន់) ដុល្លារអាមេរិក ។

-**បានឃើញ** ចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] យាន បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលសវនាការប្រហាក់ប្រហែលគ្នាថា ៖ ខ្លួនជាម្តាយបង្កើតរបស់ឈ្មោះ [redacted] សុភ័ក្រ ភេទស្រី អាយុ១៥ឆ្នាំ នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ វេលាម៉ោង ១៩ និង០០នាទី ខ្លួនបានបាត់កូនឈ្មោះ [redacted] សុភ័ក្រ ដោយមិនបានដឹងថាទៅណាទេ ។ រហូតដល់ថ្ងៃស្អែក មានអ្នកលក់ឡាននិយាយថា មានជនបរទេសម្នាក់បានលួងលោមក្មេងស្រីចំនួន ៣នាក់ [redacted] នរបងកោះពេជ្រ វេលាម៉ោង ២២ និង ០០នាទី ហើយត្រូវសមត្ថកិច្ចចាប់ខ្លួនបាន ។ ចំពោះរឿងហេតុដែលជនបរទេសនោះ ហៅ [redacted] ខ្លួនមិនបានឃើញទេ ដឹងតាមកូនប្រាប់តែប៉ុណ្ណោះ ក្នុងរឿងនេះ ខ្លួនប្តឹងទាមទារជម្ងឺចិត្តចំនួន ៥.០០០ (ប្រាំពាន់) ដុល្លាអាមេរិក ។

-**បានឃើញ** ចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] រឿន បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលសវនាការប្រហាក់ប្រហែលគ្នាថា ៖ ខ្លួនជាម្តាយបង្កើតរបស់ឈ្មោះ [redacted] ស្រីម៉ៅ ភេទស្រី អាយុ១៥ឆ្នាំ នៅថ្ងៃខែមិនចាំ កូនប្រសារខ្លួនឈ្មោះ [redacted] តោ បានទូរស័ព្ទប្រាប់ខ្លួនថា កូនរបស់ខ្លួនឈ្មោះ [redacted] ស្រីម៉ៅ ត្រូវខាងសាលាក្រុងចាប់ ។ ចំពោះរឿងហេតុដែលគេចាប់កូនរបស់ខ្លួន យកទៅដាក់នៅកន្លែងអង្គការ ខ្លួនមិនបានដឹងថា មានរឿងហេតុអ្វីទេ ក្រោយមកទើបខ្លួនដឹងថា មានជាប់ពាក់ព័ន្ធ និងជនបរទេសក្នុងរឿងនេះ ខ្លួនប្តឹងទាមទារជម្ងឺចិត្តចំនួន ៣០០០ (បីពាន់) ដុល្លាអាមេរិក ។



Scanned with CamScanner

-បានឃើញ ចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] រ៉ូហាន់នី បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលសវនាការប្រហាក់ប្រហែលគ្នាថា ៖ ខ្លួនជាម្តាយបង្កើតរបស់ឈ្មោះ [redacted] សុភ័នីមុន្នី ភេទស្រី អាយុ៦ឆ្នាំ នៅក្នុងខែមេសា ឆ្នាំ២០១៥ កូនស្រីរបស់ខ្លួនបានប្រាប់ខ្លួនថា ជនបរទេសម្នាក់ដែលមកជួលផ្ទះ នៅអាគារបេ ជាន់ទី៦ បានហៅវា ឱ្យទៅលើផ្ទះរបស់ជនបរទេសនោះ ។ ដំបូងជនបរទេសនោះបានប្រាប់កូនខ្លួនថា ឱ្យឡើងទៅយកលុយ ស្រាប់តែជនបរទេសនោះបានចាប់ដៃកូនស្រីខ្លួន [redacted]តកូនខ្លួនបានចុះមកក្រោមវិញ ។ ចំពោះរឿងហេតុដែលជនបរទេសនោះ ហៅកូនខ្លួ[redacted]ដឹងតាមកូនប្រាប់តែប៉ុណ្ណោះ ។ ក្នុងរឿងនេះ ខ្លួនប្តឹងទាមទារជម្ងឺចិត្តចំនួន ៥.០០០ (ប្រាំពាន់) ដុល្លាអាមេរិក ។

-បានឃើញ ចម្លើយរបស់សាក្សីឈ្មោះ [redacted] សំណាង បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ និងដំណាក់កាលស៊ើបសួរប្រហាក់ប្រហែលគ្នាថា ៖ ខ្លួនរស់នៅក្នុងសហគមន៍បុរីកីឡា ហើយធ្លាប់បានឃើញឈ្មោះ [redacted] Naswall និយាយលេងជាមួយក្មេងៗ និងទិញនំឱ្យក្មេងៗ ញ៉ាំ និងបានឃើញឈ្មោះ [redacted] Naswall បបួលឈ្មោះ ស្រីទូច ភេទស្រី អាយុ១២ឆ្នាំ ទៅដើរលេងមាត់ទន្លេ និងមុខវាំង ហើយខ្លួនបានសួរឈ្មោះស្រីទូច ថា តើឈ្មោះ[redacted] Naswall បានប៉ះពាល់រាងកាយឯងទេ? ស្រីទូច ឆ្លើយថា ឈ្មោះ [redacted] Naswall មិនបានប៉ះពាល់រាងកាយទេ ។

-បានឃើញ ចម្លើយរបស់សាក្សីឈ្មោ[redacted]កក្រា បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ និងដំណាក់កាលស៊ើបសួរប្រហាក់ប្រហែលគ្នាថា ៖ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៣ វេលាម៉ោង ២១និង០០នាទី ខ្លួនកំពុងសុំលុយភ្ញៀវបរទេសតាមផ្លូវលេខ១៣៦ ជិតផ្សារកណ្តាល ក៏បានជួបជនបរទេសឈ្មោះ [redacted] Naswall ហើយបានឱ្យប្រាក់ចំនួន ១ដុល្លា រួចឈ្មោះ [redacted] Naswall បានបបួលខ្លួនទៅដេកជាមួយគេដោយសន្យាឱ្យប្រាក់ ២០ដុល្លា បន្ថែមទៀតបើខ្លួនព្រមទៅ ។ គាត់និយាយជាភាសាអង់គ្លេស តែខ្លួនចេះស្តាប់បន្តិចបន្តួច ។ នៅថ្ងៃបន្ទាប់មកទៀតខ្លួនព្រមទាំងមិត្តភក្រ្ត ៥នាក់ទៀត ទៅហូបបាយរួចឈ្មោះ [redacted] Naswall បាននិយាយប្រាប់ខ្លួន និងមិត្តភក្រថា ស្អែករូបគេវិលទៅសហរដ្ឋអាមេរិកវិញហើយ ។

-បានឃើញ ចម្លើយរបស់សាក្សីឈ្មោះ [redacted] ស្រីនាង បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ និងដំណាក់កាលស៊ើបសួរប្រហាក់ប្រហែលគ្នាថា ៖ កាលពីថ្ងៃខែមិនចាំ ឆ្នាំ២០១៣ ខ្លួនធ្លាប់បានជួបជនបរទេសឈ្មោះ [redacted] Naswall នៅមុខវាំង បានបបួលខ្លួនឱ្យទៅជាមួយគេ តែខ្លួនប្រកែក ។ ថ្ងៃមួយ [redacted] Naswall បានបបួលប្រពន្ធគេទៅដេកនៅផ្ទះសំណាក់ ប្តីគេដឹងក៏ព្រួតវាយបណ្តាលឱ្យបែកក្បាល នៅជិតផ្សារសុរិយាម៉ល ។ ឈ្មោះ [redacted] Naswall បបួលខ្លួនទៅដេកនៅផ្ទះសំណាក់ គាត់ឱ្យប្រាក់ តែខ្លួនមិនព្រមទៅទេ ។ លុះនៅថ្ងៃបន្ទាប់មកទៀតឈ្មោះ [redacted] Naswall បានបបួលខ្លួនទៅដើរលេងនៅកោះពេជ្រ ពេលនោះមានមិត្តភ័ក្រចំនួន ០២នាក់ទៀត មានឈ្មោះ ស្រី ណែត និងឈ្មោះ ស្រី វ៉ាន ទៅដល់ជិតស្ពានកោះពេជ្រខាងត្បូង នៅម៉ោង ២៤ និង០០នាទី ឈ្មោះ [redacted] Naswall បានឈប់ម៉ូតូ រួចបាន[redacted]ខ្លួនក៏ដើរចេញទៅតល់ស្ពាន ។ បន្តិចក្រោយមកខ្លួនបានក្រឡេកឃើញឈ្មោ[redacted] Naswall [redacted]ញឱ្យ ស្រី ណែត និងឈ្មោះ ស្រី វ៉ាន លេ[redacted]បានមួយសន្ទុះឃើញឈ្មោះ [redacted] Naswall ឱ្យលុយទៅ ស្រី ណែត និងឈ្មោះ ស្រី វ៉ាន មិនដឹងថា ប៉ុន្មានទេ ។



Scanned with CamScanner

-បានឃើញ ចម្លើយរបស់សាក្សីឈ្មោ[redacted] ស្រីពីប បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ថា ៖ នៅថ្ងៃមិនចាំ ខែមិថុនា ឆ្នាំ២០១៣ ខ្លួនបានជួបឈ្មោ[redacted]Naswall នៅមុខផ្ទះ គាត់បាននាំពួកខ្លួនដើរលេងផ្សារស៊ីធីម៉ល គាត់ឱ្យលុយខ្លួនចំនួន ៥.០០០ រៀល ទិញកាក់ហ្គេម និងទិញការ៉េមញ៉ាំ ខ្លួនបានឃើញឈ្មោះ [redacted]Naswall អោបពីក្រោយខ្នងកាទូច ពេលជិះកង់បី ។ នៅក្នុងខែធ្នូ ឆ្នាំ២០១៣ ខ្លួនបានឃើញឈ្មោះ[redacted]Naswall ឱ្យប្រាក់២១ដុល្លារអាមេរិក ទៅឈ្មោះ ធូ ។

-បានឃើញ ចម្លើយរបស់សាក្សីឈ្មោ[redacted] ចន្ទ បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ និងដំណាក់កាលស៊ើបសួរប្រហាក់ប្រហែលគ្នាថា ៖ ខ្លួនបានស្គាល់ជនបរទេសនោះតែមិនស្គាល់ឈ្មោះទេ ហើយខ្លួនឃើញគាត់ឧស្សាហ៍មកលេងជាមួយក្មេងៗ នៅមុំផ្ទះខ្លួន ហើយក្មេងៗក៏បានសុំប្រាក់ពីគាត់ផងដែរ ។ ឃើញគាត់នៅខាងក្រោយ និយាយលេងជាមួយក្មេងៗ គាត់បានឱ្យប្រាក់ទៅក្មេងៗមាន ១ដុល្លា ២ដុល្លា ៥០០រៀល និង១០០រៀល ។ ខ្លួនធ្លាប់សុំលុយគាត់ចំនួន ៤ដង បានចំនួន ៥០០រៀល ទៅ ១០០០រៀល ១ ដុល្លារ និង ២ ដុល្លារ ។ ខ្លួនមិនបានដើរលេង ឬឡើងផ្ទះរបស់ឈ្មោ[redacted]Naswall ទេ ។

-បានឃើញ ចម្លើយរបស់សាក្សីឈ្មោះ[redacted]កែវ បានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ និងដំណាក់កាលសវនាការប្រហាក់ប្រហែលគ្នាថា ៖ នៅយប់ថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០១៥ វេលាម៉ោង ២២ និង ២០នាទី ខ្លួនបានឃើញជនបរទេសម្នាក់ បានជិះម៉ូតូឌុបក្មេងស្រី ០៣នាក់ មកឈប់ម៉ូតូនៅខាងក្រោយឃ្លាំងដាក់ឥវ៉ាន់ រួចជនបរទេស នោះបានឱ្យក្មេងស្រីតូចៗ នោះអង្គុយលើម៉ូតូ រួចជនបរទេសនោ[redacted]ប្រហែល២នាទី និងរយៈពេល ៥នាទី ក្រោយមកឃើញជនបរទេសនោះ [redacted]ៗម្តងទៀត ។ បន្ទាប់ក៏មានសមត្ថកិច្ចធ្វើការឃាត់ខ្លួនតែម្តង ។

-បានឃើញ ចម្លើយរបស់សាក្សីឈ្មោ[redacted] សុខឡេង បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា ៖ កាលពីមុនខ្លួននៅអង្គការមិត្តសំលាញ់ រៀនបានប្រហែល១ឆ្នាំ ក៏បានទៅរៀននៅសាលារដ្ឋ (ហាងង៉ោស្រះចក) បានបួនឆ្នាំ ក៏ឈប់រៀន ។ ខ្លួនក៏ដើររើសអេតចាយ និងសុំលុយពីភ្ញៀវនៅតាមមាត់ទន្លេជាមួយមិត្តភ័ក្រមានឈ្មោះ សុភ័ក្រ, ឈ្មោះ ពេជ្រ, ឈ្មោះ ក្លាម, ឈ្មោះ ភី ហៅ រ័ត្ន, និងឈ្មោះ ៣៧ ដើរពីម៉ោង ៦ ដល់ម៉ោង ៩ យប់ ខ្លួនមកផ្ទះវិញ ។ ខ្លួនធ្លាប់ស្គាល់ជនបរទេស មានឈ្មោះ អាឆ្កែ (ប្រាយអិន) ត្រិះស្មៀន, ឈ្មោះ តូនី ខ្លួនមិនបានលុយពីភ្ញៀវទេ ខ្លួនឃើញឈ្មោះ សុភ័ក្រ, ឈ្មោះ ពេជ្រ និងឈ្មោះ រ័ត្ន ជិះម៉ូតូជាមួយឈ្មោះ អាឆ្កែ (ប្រាយអិន) ៣ ទៅ ៤ដង ។ ពេលពួកគេត្រឡប់មកវិញ ឃើញពួកគេមានលុយ ១០ ដុល្លារម្នាក់ៗ ខ្លួនសួរពួកគេដែរ តែពួកគេមិនប្រាប់ ។ នៅថ្ងៃខែមិនចាំ ឆ្នាំ ២០១៤ ខ្លួនធ្លាប់ដើរលេងជាមួយឈ្មោះ[redacted] ស្មៀន នៅម៉ាត នៅ សូរិយាម៉ល ពេលខ្លះខ្លួនអង្គុយជាមួយឈ្មោះ ត្រិះស្មៀន ទល់ភ្លឺ ចាំទិញស្រាឱ្យគាត់ ។ គាត់ឱ្យលុយខ្លួន ៥ដុល្លា ប្រហែល ៤ទៅ៥ដងដែរ ខ្លួនធ្លាប់ឃើញឈ្មោះ ភ័ក្រ និងឈ្មោះ ស្រីរ័ត្ន [redacted]របស់ឈ្មោះ ត្រិះស្មៀន ៤ទៅ៥ដងដែរ (នៅក្នុងម៉ាត) និងធ្លាប់ឃើញឈ្មោះ ក្លាម, ឈ្មោះ សុភ័ក្រ, ឈ្មោះ ស្រីរ័ត្ន, ឈ្មោះ ៣៧ ទៅជាមួយឈ្មោះ តូនី ពេលពួកគេត្រឡប់មកវិញមានលុយដុល្លារ (មិនដឹងចំនួន) ហើយ ពួកក៏មិនបានប្រាប់ខ្លួនថាធ្វើអ្វីដែរ ។

-បានឃើញ ចម្លើយលោក[redacted] លីន ជានាយកការិយាល័យការពារអនីតិជនបានឆ្លើយថា ៖ នៅថ្ងៃកើតហេតុ ខ្លួនបានទទួលការរាយការណ៍ពីប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ទន្លេបាសាក់ មានករណីរំលោភបំពានផ្លូវភេទលើកុមារ នៅលើកោះពេជ្រ ហើយកំលាំងរបស់លោកក៏បានចុះទៅតាមការរាយការណ៍របស់



Scanned with CamScanner

សន្តិសុខ និងនគរបាលប៉ុស្តិ៍ រហូតដល់ឈានដល់ការឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] Naswall ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិអាមេរិក មកសួរនាំនៅកន្លែងសមត្ថកិច្ចរបស់ខ្លួន ។

**-បានឃើញ** សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ : **២១៣ -ច-ក្រ៣ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦ ដែលមានខ្លឹមសារដូចតទៅ ៖**

១-ផ្តន្ទាទោសឈ្មោះ [redacted] Naswall ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិអាមេរិក ដាក់ពន្ធនាគាររយៈពេល ១០(ដប់)ឆ្នាំ ពីបទ ការទិញសេវាផ្លូវភេទកុមារ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ ២០១១, ឆ្នាំ ២០១៣, ឆ្នាំ២០១៥ និងជាក់ស្តែងនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០១៥ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញតិមាត្រា ៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

២-បង្គាប់ឱ្យឈ្មោះ [redacted] Naswall សងការខូចខាត និងជម្ងឺចិត្តទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីដូចខាងក្រោម ៖

ក.ឈ្មោះ [redacted] សុខន ចំនួន ៨.០០០.០០០ (ប្រាំបីលាន)រៀល

ខ.ឈ្មោះ [redacted] ស្រី ចំនួន ៨.០០០.០០០ (ប្រាំបីលាន)រៀល

គ.ឈ្មោះ [redacted] សុខា ចំនួន ៨.០០០.០០០ (ប្រាំបីលាន)រៀល

ឃ.ឈ្មោះ [redacted] យាន ចំនួន ៨.០០០.០០០ (ប្រាំបីលាន)រៀល

ង.ឈ្មោះ [redacted] រឿន ចំនួន ៨.០០០.០០០ (ប្រាំបីលាន)រៀល

ច.ឈ្មោះ [redacted] ហាន់នី ចំនួន ៨.០០០.០០០ (ប្រាំបីលាន)រៀល

ច្រានចោលការទាមទារលើសពីនេះ។

៣-វត្ថុតាងរួមមាន៖

ក.វត្ថុតាងសម្រេចរឹបអូស មាន៖

- Speaker (ប្រដាប់បំពងសម្លេងចំនួន ០២)
- មេម៉ូរីចំនួន ០៤ (ម៉ាក Panasinic 1GB, Wintec 4GB, Sandisk 4GB ០១គ្រឿងទៀតមិនស្គាល់ម៉ាក) ។
- CardReader ចំនួន (ម៉ាក Targus និងម៉ាកSiyoteam), ផ្លាសពណ៌ខ្មៅចំនួន ០១ជើង Memory ចំនួន ០១ និងស៊ីមកាតចំនួន ០៣ ។
- លឹង្គសប្បនិមិត្ត ចំនួន ០២ និងថ្នាំ ម៉ាក KY ចំនួន ០១ប្រអប់ ស្រោមអនាម័យ ចំនួន ០៥។
- ដំបងដែកចំនួន ០១, កាំបិតបត់ចំនួន ០៣ កាំភ្លើងជ័រចំនួន ០១ និងពិលចំនួន ០១។
- សៀវភៅកំណត់ហេតុចំនួន ០៥ក្បាល និងត្រាចំនួន ០១
- ឯកសារផ្សេងៗមួយចំនួន, ឱសថមួយចំនួន, នាមប័ណ្ណមួយចំនួនធំ និងឯកសណ្ឋានអាវប្រយុទ្ធ ០១, អាវប៉ារ៉ា ០២ ។

ខ.វត្ថុតាងដែលត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ មាន៖

- ប៉ាស្ព័រមួយក្បាលលេខ៤៥៣៦៥១៥៩១ របស់ឈ្មោះ [redacted]DAVID, ប័ណ្ណបើកបររបស់ឈ្មោះ NASWALL [redacted] ចំនួន០១, កាតអេធីអ៊ឹម ធនាគារវឌ្ឍនៈ របស់ឈ្មោះ



Scanned with CamScanner

[redacted] DAVID ចំនួន ០១, Passport Card របស់ឈ្មោះ: [redacted] DAVID ចំនួន ០១ ។

- ម៉ូតូមួយគ្រឿងម៉ាក HONDA XL125 ពណ៌ស្លាទុំ ពាក់ស្លាកលេខ ភព១ នខ១២៧ ។

- លុយចំនួន ០៣ដុល្លារអាមេរិក និងលុយខ្មែរចំនួន ១៨.៥០០រៀល ។

៤. សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ ជនរងគ្រោះ មេធាវីការពារជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៤ ខែ មិថុនា ឆ្នាំ២០១៦។

បើកទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**បានឃើញ** សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ៤៤១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៦ របស់ឈ្មោះ [redacted] Naswall ភេទប្រុស អាយុ៥៣ឆ្នាំ សញ្ជាតិអាមេរិក ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ : ២១៣ "ច" ក្រ៣ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុច : នៃសេចក្តីសម្រេចទាំងមូលនៃសាលក្រម ។

**-បានឃើញ របាយការណ៍របស់សាលាឧទ្ធរណ៍។**

**-បានឃើញ សេចក្តីសន្និដ្ឋានរបស់មហាអយ្យការ។**

**នាពេលសវនាការ**

**-ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុ។**

**-ជនជាប់ចោទឈ្មោះ** [redacted] Naswall **ឆ្លើយថា** ៖ មូលហេតុដែលខ្លួនប្តឹងឧទ្ធរណ៍គឺទីមួយការចោទប្រកាន់មិនសមរម្យចំពោះអ្វីដែលបានកើតឡើង និងខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់។ ខ្លួនពុំមានលុយឲ្យគាត់ទេ អ្វីដែលគាត់និយាយគឺមិនត្រឹមត្រូវទេ ខ្លួនពុំបានហៅគាត់ទៅកោះពេជ្រជាមួយទេ។ នៅពេលរសៀលកូនខ្លួនឈឺក៏បានជិះតុកតុកទៅDream Land ដោយសារខ្លួនបានសន្យាសុំពួកគាត់នៅជាមួយនិងកូនខ្លួនទៅដើរលេងគប់ប៉េងប៉ោងជាដើម។ ខ្លួនពុំបានអោយក្មេងៗលេងប្រដាប់ភេទទេ ហើយក៏ពុំបានលេងប្រដាប់ភេទក្មេងនោះដែរ ។ខ្លួនធ្លាប់ទិញសំបុត្រជិះកន្រ្តកវិលឲ្យពួកគាត់ ប្អូនស្រីដែលខ្ពស់នោះបានសុំចូលបន្ទប់ទឹកស្រាប់តែមានប៉ូលីស និងខាងអង្គការបានមកចាប់ តែពេលនោះខ្លួនពុំបានធ្វើអ្វីនោះទេ។ ដូច្នេះក្នុងរឿងនេះមិនដូចការចោទប្រកាន់ទេ ឈ្មោះក្មេងស្រីដែលបានអានឲ្យខ្លួនស្តាប់នេះ មិនដែលឈ្លោះគ្នាជាមួយខ្លួនទេ តែអាចធ្លាប់ឈ្លោះជាមួយសាច់ញាតិខ្លួនពេលលក់សៀវភៅ។ ខ្លួនមិនធ្លាប់មានទំនាស់ទេ នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៥ អង្គហេតុដែលត្រូវបានឃាត់ខ្លួននោះមានក្មេងស្រី០៥ទៅ០៦នាក់ ហើយខ្លួនតែម្នាក់ខ្ពស់នោះទេ ម្នាក់ទៀតមិនស្គាល់ទេ។ ខ្លួនធ្លាប់ឌុបក្មេកស្រី៣នាក់ទៅកោះពេជ្រ។ មុនពេលឃាត់ខ្លួន ខ្លួនបានទូរស័ព្ទទៅFBI របស់អាមេរិក គេបញ្ជាក់ថាខ្លួនគ្មានបានប្រព្រឹត្តបទល្មើសអ្វីទេ។ ខ្លួនធ្លាប់មានទំនាស់ជាមួយអង្គការ អេផល ដែលអង្គការ អេផល ចង់ធ្វើបាបខ្លួន ដោយឲ្យក្មេងស្រីម្នាក់រត់មករកខ្លួន រួចថតរូប។ អង្គការអេផល ធ្លាប់និយាយក្នុងការសែតថា ខ្លួនធ្លាប់ប្រព្រឹត្តអាណាចារ្យជាក់ស្តែងពុំមែនជាការពិត។ខ្លួនគ្រាន់តែដឹកក្មេងស្រី៣នាក់នេះមិនបានប្រព្រឹត្តអ្វីខុសទេ ហើយរបស់របរដូចជាស្រោមអនាម័យ លីង្គសប្បនិមិត្តជារបស់ធម្មតាសម្រាប់ប្រើប្រាស់ធម្មតានៅក្នុងផ្ទះ។ ស្នើសុំតុលាការ រួចផុតពីបទចោទ និងដោះលែងមានសេរីភាពឡើងវិញ។



Scanned with CamScanner

-ជនរងគ្រោះឈ្មោះ [redacted] ស្រីល័ក្ខ ឆ្លើយថា៖ គាត់អោយខ្លួនអង្គុយលើម៉ូតូខាងមុខគាត់ គាត់ស្រាត [redacted]គាត់សន្យាឲ្យលុយខ្លួន១៥ រឺ២០ដុល្លារ ខ្លួនមិនចាំ។

-ជនរងគ្រោះឈ្មោះ[redacted] សុភ័ក្រ ឆ្លើយថា៖ គាត់នាំខ្លួនដើរលេងគ្រប់ម៉ោង គាត់នាំខ្លួនទៅជិះម៉ូតូជាមួយគាត់ នាំខ្លួនទៅលេងកោះពេជ្រឲ្យខ្លួនសាប់ក្ដគាត់ រួចគាត់ឲ្យលុយ៥ដុល្លារ នៅកន្លែងស្ងាត់ៗ ៤ទៅ៥ដង តែគាត់មិនដែលរួមភេទជាមួយខ្លួនទេ [redacted]ដែលនៅកន្លែងកោះពេជ្រ និងនៅកន្រ្ទកវិល។ គាត់និយាយថា យូ ផ្លេ ហាត ដក មី អាយគីវ យូ ហ្វាយដុល្លារ ដែលពេលនោះគាត់និយាយខ្លួនក៏យល់[redacted]

-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន៖ តាមភស្តុតាងដែលមានក្នុងសំណុំរឿង និងការបញ្ជាក់របស់ជនរងគ្រោះ និងជនជាប់ចោទបញ្ជាក់ថា ជនជាប់ចោទ និងជនរងគ្រោះពិតជាស្គាល់គ្នា។ ចម្លើយជនជាប់ចោទឆ្លើយបដិសេធថា ពុំបានទិញពេស្យាចារកុមារទេ។ ជនរងគ្រោះបានឆ្លើយថា មានការទិញពេស្យាចារដែលអាចជឿបានថា មានការទិញពេស្យាចារកុមារ ចម្លើយជនជាប់ចោទគ្រាន់តែជាចម្លើយដោះសារតែប៉ុណ្ណោះ ស្នើសុំក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមទុកជាបានការដដែល។

-មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋាន៖ ឆ្លងកាត់តាមការពិភាក្សាដេញដោលបង្ហាញថា ពិតជាការប្រព្រឹត្ត ការទិញពេស្យាចារកុមារពិតមែន ទោះជាឆ្លើយបដិសេធក៏ដោយ ស្នើសុំក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន៖កូនក្តីខ្លួនបានឆ្លើយបដិសេធគ្រប់ដំណាក់កាលគ្មានភស្តុតាងណាមួយមកបញ្ជាក់ច្បាស់លាស់ទេ។ ការចោទប្រកាន់មកលើកូនក្តីខ្លួន គឺគ្មានភស្តុតាងច្បាស់លាស់ ចម្លើយបដិសេធគឺសមស្រប ស្នើសុំលើកលែងការចោទប្រកាន់ និង ដោះលែងកូនក្តីខ្លួនឲ្យមានសេរីភាពឡើងវិញ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះ
- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យគ្រប់ឯកសារ និងភស្តុតាងផ្សេងៗ
- ក្រោយពីបានពិភាក្សាជាក្រុមប្រឹក្សាត្រឹមត្រូវតាមច្បាប់ហើយ
- ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

**<u>សភាព្រហ្មទណ្ឌ</u>**

**<u>យល់ឃើញថា</u>**

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខ៨៤១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] Naswall ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២១៣ "ច"ក្រ៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ ត្រង់ចំណុចសេចក្តីវិនិច្ឆ័យទាំងមូល របស់សាលដំបូងរាជធានីភ្នំពេញ បណ្តឹងធ្វើឡើងក្នុង



Scanned with CamScanner

កំណត់ច្បាប់យោងតាមបញ្ញត្តិមាត្រា៣៧៥ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] Naswall បានឆ្លើយ នាពេលសវនាការសាលាឧទ្ធរណ៍ថា មូលហេតុដែលខ្លួនប្តឹងឧទ្ធរណ៍គឺទីមួយ ការចោទប្រកាន់មិនសមរម្យចំពោះអ្វីដែលបានកើតឡើង និងខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់។ ខ្លួនពុំមានលុយឲ្យគាត់ទេ អ្វីដែលគាត់និយាយគឺមិនត្រឹមត្រូវទេខ្លួនពុំបានហៅគាត់ទៅកោះពេជ្រជាមួយទេ។ នៅពេលរសៀលកូនខ្លួនឈឺក៏បានជិះតុកតុកទៅDream Land ដោយសារខ្លួនបានសន្យាសុំពួកគាត់នៅជាមួយនិងកូនខ្លួនទៅដើរលេងគប់ប៉េងប៉ោងជាដើម។ ខ្លួនពុំបា[redacted]ហើយក៏[redacted]ដែរ។ ខ្លួនធ្លាប់ទិញសំបុត្រជិះកន្ត្រកវិលឲ្យពួកគាត់ ប្អូនស្រីដែលខ្ពស់នោះបានសុំចូលបន្ទប់ទឹកស្រាប់តែមានប៉ូលីស និងខាងអង្គការបានមកចាប់ តែពេលនោះខ្លួនពុំបានធ្វើអ្វីនោះទេ។ ដូច្នេះក្នុងរឿងនេះមិនដូចការចោទប្រកាន់ទេ ឈ្មោះក្មេងស្រីដែលបានអានឲ្យខ្លួនស្តាប់នេះ មិនដែលឈ្មោះគ្នាជាមួយខ្លួនទេ តែអាចធ្លាប់ឈ្មោះជាមួយសាច់ញាតិខ្លួនពេលលក់សៀវភៅ។ ខ្លួនមិនធ្លាប់មានទំនាស់ទេ នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៥ អង្គហេតុដែលត្រូវបានឃាត់ខ្លួននោះមានក្មេងស្រី០៥ទៅ០៦នាក់ ហើយខ្លួនតែម្នាក់ខ្ពស់នោះទេ ម្នាក់ទៀតមិនស្គាល់ទេ។ ខ្លួនធ្លាប់ឧបក្មេកស្រី៣នាក់ទៅកោះពេជ្រ។ មុនពេលឃាត់ខ្លួន ខ្លួនបានទូរស័ព្ទទៅFBI របស់អាមេរិក គេបញ្ជាក់ថាខ្លួនគ្មានបានប្រព្រឹត្តបទល្មើសអ្វីទេ។ ខ្លួនធ្លាប់មានទំនាស់ជាមួយអង្គការ អេ ផល ដែលអង្គការ អេ ផល ចង់ធ្វើបាបខ្លួន ដោយឲ្យក្មេងស្រីម្នាក់រត់មករកខ្លួន រួចថតរូប។អង្គការ អេផល ធ្លាប់និយាយក្នុងការសែតថា ខ្លួនធ្លាប់ប្រព្រឹត្តអាណាចារ្យជាក់ស្តែងពុំមែនជាការពិត។ ខ្លួនគ្រាន់តែដឹកក្មេងស្រី៣នាក់នេះមិនបានប្រព្រឹត្តអ្វីខុសទេ ហើយរបស់របរដូចជាស្រោមអនាម័យលឹង្គសប្បនិមិត្តជារបស់ធម្មតាសម្រាប់ប្រើប្រាស់ធម្មតានៅក្នុងផ្ទះ។ ស្នើសុំតុលាការ រួចផុតពីបទចោទ និងដោះលែងមានសេរីភាពឡើងវិញ។

ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា ទោះបីជនជាប់ចោទមិនបានឆ្លើយសារភាពកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តនៅគ្រប់ដំណាក់កាល ដល់នាពេលសវនាការសាលាឧទ្ធរណ៍ តែបើតាមការពិនិត្យទៅលើអង្គហេតុរួមទាំងភស្តុតាងពាក់ព័ន្ធនៅក្នុងសំណុំរឿង និងអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីម៉ៅ, [redacted] មុន្នីវត្ន [redacted] ស្រីឃឹម, [redacted] សុភីនីជុតិមុន្នី, [redacted] ស្រីណែត, [redacted] សុភ័ក្រ, [redacted] ស្រីរ័ត្ន [redacted] ស្រីល័ក្ខ,និងឈ្មោះ [redacted] ស្រីពៅ បានឆ្លើយប្រហាក់ប្រហែលគ្នាថា ខ្លួនស្គាល់ឈ្មោះ [redacted] Naswall តាំងពីឆ្នាំ ២០១៤ នៅពេលដែលខ្លួនបានដើររើសអេតចាយនៅមាត់ទន្លេ និងគាត់ធ្លាប់ឱ្យប្រាក់មកខ្លួនចំនួន ៣ដង ពី១ដង ទៅ ៥០០០រៀល និងធ្លាប់ដើរលេងជាមួយគាត់បានចំនួន ៣ដង ដែរ និ[redacted] គាត់បានឱ្យប្រាក់ ១០ដុល្លារ ។ នៅថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៥ វេលាម៉ោង ២០ និង០០នាទី ខ្លួនបានឱ្យប្រាក់ ១០ដុល្លារ ។ នៅថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១៥ វេលាម៉ោង ២០ និង ០០នាទី ខ្លួនបានជួបឈ្មោះ E[redacted] [redacted] Naswall រួចក៏បបួលពួកខ្លួន ជិះម៉ូតូដើរលេង មានខ្លួន ,ឈ្មោះ [redacted] ភ័ក្រ និងឈ្មោះ ស្រី រ័ត្ន ចំណែកឈ្មោះ ស្រី ពៅ មិនបានទៅទេ ។ ក្នុងពេលពួកខ្លួនជិះកន្ត្រកវិល ជាមួយឈ្មោះ E[redacted] Naswall គឺគាត់ឱ្យពួកខ្លួនទាំងបី [redacted] ឱ្យពួកខ្លួនលេង ហើយឈ្មោះ [redacted] Naswall ក៏[redacted]ដែរ ហូតដល់កន្ត្រកលែងវិលទើបឈប់លេង ។ ឈ្មោះ [redacted] Naswall បានសន្យាឱ្យប្រាក់ក្នុងម្នាក់ៗ ១០ដុល្លារ ។ បន្ទាប់មកក៏បានឧបពួកខ្លួនទៅកោះពេជ្រពេលទៅដល់កន្លែងមួយដែលគេព័ទ្ធសង្ក័សីជិតសន្តិសុខយាម យប់



Scanned with CamScanner

ស្នាក់ឈ្មោះ [redacted] Naswall ក៏បានឱ្យពួកខ្លួនទាំងបីនាក់ លេងប្រដាប់ភេទរបស់គាត់ទៀត ដោយបានសន្យាឱ្យប្រាក់មកខ្លួន និងឈ្មោះ ស្រីរ័ត្ន ក្នុងម្នាក់ ៥ដុល្លាថែមទៀត ចំណែកឈ្មោះ [redacted] ល័ក្ខ គឺគាត់ថែមឱ្យ ១០ដុល្លារ ។ ពេលនោះខ្លួន និងឈ្មោះ ស្រី ល័ក្ខ មិនបានលេងទេ ហើយឈ្មោ [redacted] Naswall ក៏ឱ្យពួកខ្លួនទាំងពីរឈរឆ្ងាយ ដើម្បីចាំមើលផ្លូវឱ្យគាត់។ ពេលនោះខ្លួនឃើញឈ្មោះ [redacted] Naswall [redacted] ាក់នាងឱ្យអង្គុយលើម៉ូតូ ហើយឈ្មោះ [redacted] Naswall [redacted] ស្រីល័ក្ខ ពេលនោះខ្លួនក៏ងាកមុខចេញ ស្រាប់តែមានសមត្ថកិច្ចមកចុះចាប់ខ្លួនតែម្តង។ កន្លងមកពេលដែលខ្លួនដើរលេងជាមួយឈ្មោះ [redacted] ណែត និងឈ្មោះ ស្រី ម៉ៅ គឺធ្លាប់បានឃើញឈ្មោះ [redacted] Naswall ឱ្យឈ្មោះ ស្រីម៉ៅ និងឈ្មោះ ស្រីណែត [redacted] របស់គាត់នៅកោះពេជ្រផងដែរ។ ប៉ុន្តែមិនបានដឹងថាឈ្មោះ [redacted] Naswall ឱ្យលុយទៅឈ្មោះ [redacted] ម៉ៅ និង ស្រី ណែត ប៉ុន្មានទេ ដែលមានភាពស៊ីចង្វាក់គ្នាទៅនឹងអង្គហេតុ នេះបញ្ជាក់ថា ជនជាប់ចោទឈ្មោ [redacted] Naswall ពិតជាបានប្រព្រឹត្តអំពើទិញសេវាផ្លូវភេទលើកុមារ ពិតប្រាកដមែន ដូច្នេះគប្បីពិនិត្យ និងសម្រេចតាមច្បាប់។

៣-សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា តាមភស្តុតាងដែលមានក្នុងសំណុំរឿង និងការបញ្ជាក់របស់ជនរងគ្រោះ និងជនជាប់ចោទបញ្ជាក់ថា ជនជាប់ចោទ និងជនរងគ្រោះពិតជាស្គាល់គ្នា។ ចម្លើយជនជាប់ចោទឆ្លើយបដិសេធថា ពុំបានទិញសេវាផ្លូវភេទកុមារទេ។ ជនរងគ្រោះបានឆ្លើយថា មានការទិញសេវាផ្លូវភេទ ដែលជឿបានថា មានការទិញសេវាផ្លូវភេទពីកុមារ ចម្លើយជនជាប់ចោទគ្រាន់តែជាចម្លើយដោះសារតែប៉ុណ្ណោះ ស្នើសុំតម្កល់ទុកជាបានការ។ ក្រុមប្រឹក្សាយល់ឃើញថា សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការមានលក្ខណៈត្រឹមត្រូវ ដូច្នេះគប្បីក្រុមប្រឹក្សាសម្រេចតាមច្បាប់ ។

៤-សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី ឆ្លងកាត់តាមការពិភាក្សាដេញដោលបង្ហាញថា ពិតជាការប្រព្រឹត្ត ការទិញសេវាផ្លូវភេទកុមារពិតមែន ទោះជាឆ្លើយបដិសេធក៏ដោយ ស្នើសុំតម្កល់សាលក្រម។ ក្រុមប្រឹក្សាយល់ឃើញថា សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានលក្ខណៈត្រឹមត្រូវ គប្បីក្រុមប្រឹក្សាលើមកពិចារណា និងសម្រេចតាមច្បាប់។

៥-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនបានឆ្លើយបដិសេធគ្រប់ដំណាក់កាល គ្មានភស្តុតាងណាមួយមកបញ្ជាក់ច្បាស់លាស់។ ការចោទប្រកាន់មកលើកូនក្តីខ្លួនគឺគ្មានភស្តុតាង ចម្លើយបដិសេធគឺសមស្រប ស្នើសុំលើកលែងការចោទប្រកាន់ និង ដោះលែងកូនក្តីខ្លួនឲ្យមានសេរីភាពឡើងវិញ។ ក្រុមប្រឹក្សាយល់ឃើញថា សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទពុំមានលក្ខណៈត្រឹមត្រូវ ដោយហេតុថា ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីដោះបន្ទុកទៅលើកូនក្តីរបស់ខ្លួន និងសាក្សីណាមួយ ដែលអាចអោយក្រុមប្រឹក្សាជឿបានឡើយ ព្រោះបើតាមពិនិត្យទៅលើឯកសារដែលមាននៅក្នុងសំណុំរឿង ឃើញថា មានចម្លើយជនរងគ្រោះឈ្មោ [redacted] ស្រីល័ក្ខ និង [redacted] សុភ័ក្រ នាពេលសវនាការសាលាឧទ្ធរណ៍ បានឆ្លើយប្រហាក់ប្រហែលគ្នាថា ជនជាប់ចោទនាំខ្លួនដើរលេងគ្រប់ម៉ោង ជនជាប់ចោទនាំខ្លួនទៅជិះម៉ូតូជាមួយ នាំខ្លួនទៅលេង [redacted] ចគាត់ឲ្យលុយ៥ដុល្លារ នៅកន្លែងស្ងាត់ៗ ៤ទៅ៥ដង តែជនជាប់ចោទមិនដែលរួមភេទជាមួយខ្លួនទេ គ្រាន់ [redacted] កាះពេជ្រ និងនៅកន្ត្រកវិល។ ជនជាប់ចោទនិយាយថា យូ ផ្លេ ហាត ដក មី អាយគីវ យូ ហ្វាយដុល្លារ ដែលពេលនោះគាត់និយាយខ្លួនក៏យល់ព្រមថា [redacted] និងចម្លើយសាក្សីដ៏ទៃ ដែលមានភាពស៊ីចង្វាក់គ្នា បញ្ជាក់អោយក្រុម



Scanned with CamScanner

ប្រឹក្សាឃើញថា ជនជាប់ចោទរូបនេះពិតជាមានពិរុទ្ធភាពដូចការចោទប្រកាន់ ដូច្នេះគប្បីក្រុមប្រឹក្សាពិនិត្យ និងសម្រេចតាមច្បាប់។

៦-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted]aswall ពីបទ ទិញពេស្យាចារកុមារ ប្រព្រឹត្ត នៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១១ ឆ្នាំ២០១៣ ឆ្នាំ២០១៥ និងជាក់ស្តែងនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

៧-សាលក្រមព្រហ្មទណ្ឌលេខ ២១៣ "ច"ក្រ៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្តី មានលក្ខណៈត្រឹមត្រូវ ដែលសមស្របទៅនឹងអំពើរបស់ជនជាប់ចោទរូបនេះបានប្រព្រឹត្ត និង ព្យសនកម្មដែលជនរងគ្រោះទទួលរងហើយ ដូច្នេះគប្បីក្រុមប្រឹក្សាតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤៤១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] Naswall ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ២១៣"ច"ក្រ៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ។

៣-បន្តឃុំខ្លួនឈ្មោ[redacted] Naswall ដែលមានសញ្ជាតិដូចខាងលើតាមនីតិវិធី។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០២០ និង ប្រកាសជាសាធារណៈនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ ចំពោះមុខឈ្មោះ [redacted] Naswall និង ចាត់ទុកជាចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខន , [redacted] ស្រី, [redacted]សុខា, [redacted] ឃាន [redacted] រឿន, [redacted]ហាន់នី។

ទុកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃចន្ទ ៦កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០

បានឃើញ

ប្រធានក្រុមប្រឹក្សា

[redacted]

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner